**Program:** ឃាតកម្មមុនចូលគេង

**Topic:** Victor Ernest Hoffman

ឃាតករោគចិត្តដែលសម្លាប់ មនុស្ស ៩ នាក់

**Categories:** Crime Investigation

**Check: Done**

**Content by:** Prey Reung

---

សូមស្វាគមន៏មកCamID Podcast!

ត្រឹមតែមួយពព្រិចភ្នែកសោះ

ឃាតករោគចិត្តម្នាក់នៅសហរដ្ឋអាមេរិកបានឆក់ជីវិតសមាជិកគ្រួសារចំនួន៩នាក់ដោយគ្មានញញើតដៃ។ ហើយនៅសល់តែក្មេងម្នាក់ប៉ុណ្ណោះតែនៅរស់រានមានជីវិតពីសោតនាកម្មមួួយនេះ។ហើយអ្វីដែលនឹកស្មានមិនដល់នោះគឺឃាតកមិនមានទោសនោះទេ។នេះគឺជារឿងរ៉ាវមួយគួរអោយសោកសង្វេគចំពោះគ្រួសារមួយនេះណាស់ពីព្រោះតុលាមិនអាចទាមទារយុត្តធម៌អោយគ្រួសារនេះបានទេ គឺបានត្រឹមតែចូលរួមរំលែកទុក្ខតែប៉ុណ្ណោះ។ក្តីឃាតកម្មនេះត្រូវះបានគេអោយឈ្មោះថាដើម្បីដឹងថាសាច់រឿងនឹងទៅជាយ៉ាងណា តោះមកស្តាប់ព្រៃរឿងបកស្រាយទាំងអស់គ្នា។

រឿងរ៉ាវផ្តើមចេញពីបុរសម្នាក់ដែលមានឈ្មោះថា Victor Ernest Hoffman ។ េVictor កើតនៅឆ្នាំ ១៩៤៦ នៅលើទឹកដីប្រទេសកាណាដា ។Victor ជាមនុស្សម្នាក់ដែលមានសតិមិនគ្រប់គ្រាន់ ។តាមការស្រាវជ្រាវរបស់ព្រៃរឿង មិនមានប្រភពណាបង្ហាញពីជីវប្រវត្តរបស់Victor អោយសីុជម្រៅនោះទេ ។គ្រាន់តែដឹងថាគេគឺជាមនុស្សវិកលចរិតតែប៉ុណ្ណោះ ហើយVictor ត្រូវបានគេយកទៅព្យាបាលនៅមន្ទីពេទ្យរោគចិត្តមួយកន្លែងនៅក្នុងប្រទេសកាណាដា ។

ហេតុការណ៏ទាំងមូល គឺបានកើតឡើងនៅពេលដែលVictorចាកចេញពីមន្ទីពេទ្យបាន៣សប្តាហ៍ ដែលនៅពេលនោះគេមានអាយុ២១ ពោលគឺ នៅព្រឹកថ្ងៃទី ១៥ ខែសីហា ឆ្នាំ ១៩៦៧ Victor បានចូលទៅក្នុងកសិដ្ឋានរបស់គ្រួសារមួយដែលមានត្រកូលថា Peterson ដោយនៅក្នុងដៃរបស់គេបំពាក់ដោយកាំភ្លើងរះមួយដើម ។ សំណួរសួរថា តើមានរឿងអ្វីកើតឡើងភ្លាមៗនោះ ?

ភ្លាមៗគេបានដើរសំដៅទៅរកកន្លែងស្នាក់នៅរបស់គ្រួសារPeterson បន្ទាប់មកគេបានដក់កាំភ្លើញដែលគេកាន់មក បាញ់សម្លាប់សមាជិកទាំងអស់នៃគ្រួសារ Peterson ដែលក្នុងនោះមានកូនតូចៗចំនួន 7 នាក់ដែលVictorឈរបាញ់មានរយះចម្ងាយជិតមានចំនួនបួនបន្ទប់ ។ បើយោងទៅតាមរបាយការណ៏របស់ប៉ូលីស ការបាញ់រះទាំងអស់មានចំនួន 28គ្រាប់

ដែលក្នុងចំណោមនោះមាន 27 គ្រាប់ដែលត្រូវចំគោលដៅ មានន័យថាគ្រាប់កាំភ្លើង ២៧ គ្រាប់បានហោះត្រូវសមាជិកគ្រួសារ Peterson។

ងាយទៅមើលលោក Petersonវិញ ត្រូវបានគេបាញ់សម្លាប់នៅក្នុងផ្ទះបាយ ខណៈប្រពន្ធរបស់លោកឈ្មោះថា Evelyn និងទារកអាយុមួយឆ្នាំត្រូវបានគេរកឃើញនៅក្នុងសួនច្បារនៅខាងក្រោយផ្ទះ។ ចំណែកឯក្មេង៦នាក់របស់Petersonត្រូវបានVictorបាញ់សម្លាប់នៅពេលដែលពួកគេកំពុងដេកលក់នៅក្នុងបន្ទប់គេងរបស់ពួកគេ ដោយពួកគេទើបមានចាប់ពីអាយុ 2 ទៅ 17 ឆ្នាំតែប៉ុណ្ណោះ។មកដល់ចំណុចនេះ ក៏អ្នកទាំងអស់គ្នាអាចស្រម៉ៃបានដែរថា ពួកអ្នកទាំងនោះស្លាប់យ៉ាងអាណោចអធមជាទីបំផុត។

សំណួរសួរថា តើមានអ្នកណានៅរស់រានមានជីវិតពីសោគនាកម្មមួយនេះដែរឬទេ?

ចម្លើយគឺមាន គឺជាកូនស្រីរបស់Petersonដែលមានឈ្មោះថា Phyllis Peterson ដែលពេលនោះPhyllis មានអាយុទើបតែ 4 ឆ្នាំតែប៉ុណ្ណោះ គឺជាអ្នករស់រានមានជីវិតតែម្នាក់ឯងនៃសោគនាកម្មមួយនេះ។ តាមការពិតទៅនាងពិតជាមានសំណាងខ្លាំងណាស់ ព្រោះថានៅពេលកើតហេតុគឺនាងកំពុងតែដេកនៅក្រោមសម្លៀកបំពាក់នៅចន្លោះរវាង បងស្រីទាំងពីររបស់នាង ដូច្នេះហើយ Hoffman

មិនបានមើលឃើញ Physllis ឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយមក Hoffman បានប្រកាសថាគេបានទុកជីវិតអោយនាងដោយសារតែ "នាងមានមុខដូចជាទេវតា" ។

សាកសពទាំងអស់ ត្រូវបានអ្នកជិតខាងម្នាក់រកឃើញដោយសារគាត់នឹង ត្រូវជួយលោក Peterson ក្នុងការងារធ្វើស្រែចំការនៅព្រឹកថ្ងៃនោះ។ គាត់ត្រូវធ្វើដំណើរចម្ងាយ 6 គីឡូម៉ែត្រ ដើម្បីទៅដល់ប៉ុស្តិ៍ទូរស័ព្ទសាធារណៈ ទើបអាចរាយការណ៍ហេតុការណ៍នេះទៅកាន់ប៉ូលិសបាន។ ដោយមិនចាំយូរឡើយ ក្រោយពីប៉ូលិសទទួលបានដំណឹងនេះ ភ្លាមៗប៉ូលិសបានបើកការសុើបអង្កេតជាលក្ខណៈទ្រង់ទ្រាយធំតែម្តង។

នៅថ្ងៃទី 19 ខែសីហា ឆ្នាំ 1967 ពេលគឺបន្ទាប់ពីថ្ងៃកើតហេតុបាន៤ថ្ងៃ  Victor ត្រូវបានចាប់ខ្លួនដោយក្រុមប៉ុលិសកាណាដា ហៅកាត់ថា RCMP ដោយVictor ព្រមប្រគល់ខ្លួនអោយប៉ូលិសដោយសន្តិវិធី។ គេត្រូវបានប៉ូលិស រកឃើញនៅផ្ទះឪពុកម្តាយរបស់គេដែលមានទីតាំងស្ថិតនៅក្នុងក្រុង Leask មានចម្ងាយប្រហែល 65 គីឡូម៉ែត្រ ( 40 mi ) ភាគនិរតីនៃ Shell Lake ។

បន្ទាប់ពីការចាប់ខ្លួន គេបានប្រាប់ទៅប៉ូលីសថា មុនពេលដែលគេប្រព្រឹត្តឃាតកម្មមួយនេះ គេបានប្រយុទ្ធជាមួយនឹងពួកបិសាចទៀតផង។ ហើយបានពណ៌នាថាគេ "ខ្ពស់ខ្មៅនិងមិនមានប្រដាប់ភេទនោះទេ" ។ស្តាប់មើលទៅមានតែមនុស្សមិនគ្រប់សតិតែប៉ុណ្ណោះដែលនិយាយពាក្យនេះរួច។ Victor ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យផ្លូវចិត្តមួយនៅ North Battleford ជាកន្លែងដែលគេត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺវិកលចរិក។

ពិតជាគួរអោយសោកស្តាយចំពោះគ្រួសារទាំងមូលរបស់ Peterson ព្រោះ Victor មិនមានទោសទៅលើអំពើមនុស្សឃាតនោះទេ ដោយសារតែគេជាមនុស្សវិកលចរិក ដែលសេចក្តីសម្រេចនេះធ្វើឡើងនៅក្នុងខែកុម្ភៈឆ្នាំ 1968។ ក្នុងអំឡុងពេលសវនាការ ព្រះរាជអាជ្ញាម្នាក់គឺលោក Serge Kujawa បានហៅ Victor ថា "បុរសឆ្កួតបំផុតនៅ Saskatchewan" ។ គេត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការឃុំឃាំងរបស់មន្ទីរពេទ្យខេត្ត និងបញ្ជូនទៅស្ថាប័នព្យាបាលផ្លូវចិត្ត។

ចុងក្រោយនៅក្នុងថ្ងៃទី ២១ ខែ ឧសភា ឆ្នា២០០៤ ឃាតករោគចិត្ត Victor Ernest Hoffman ក៏បានបាត់បង់ជីវិតដោយសារតែជម្ងឺមហារីក។ហើយក៏មានអ្នកកាសែតជនជាតិកាណាដាម្នាក់ឈ្មោះថា Peter Tadman គឺនៅពេលដែលលោកកំពុងតែសរសេរសៀវភៅអំពីឃាតកម្មមួយក្នុងឆ្នាំ 1992 លោកក៏មានឱកាសសម្ភាសន៍victor ជាច្រើនដង។ បើយោងទៅតាមលោក Peter គឺVictor បានប្រាប់លោកថា  គេនៅតែមានអារម្មណ៍ថាគេគ្មានកំហុសចំពោះឃាតកម្មនេះទេ ហើយបានប្រាប់ទៀតថាគេនៅតែឃើញពួកអមនុស្សមកបង្ខំគេឱ្យប្រព្រឹត្តអំពើទាំងនេះ។សោតនាកម្មមួយនេះត្រូវបានគេអោយឈ្មោះថា The Shell Lake Murder។

ក្រោយពីអ្នកទាំងអស់គ្នាបានស្តាប់ហេតុការណ៏ដ៏រន្ធត់មួយនេះហើយ យើងអាចស្វែងយល់បានថា ថ្វីបើមនុស្សវិកលចរិកប្រព្រឹត្តអំពើមនុស្សឃាតក៏ពិតមែនក៏ប៉ុន្តែគ្រួសារទាំងត្រូវមូលត្រូវបានបាត់បង់ដោយអយុត្តិធម៌។វាអាចឆ្លុះបញ្ចាំងបានថា មានរឿងខ្លះបង្កអោយយើងគ្រោះថ្នាក់គ្រប់ពេលវេលា ដូច្នេះយើងគួរតែត្រូវចេះប្រុងប្រយ័ត្ននិច្ចមិនថានៅទីណានោះទេ។សូមស្តាប់ដោយការត្រិះរិះពិចារណា!

តើអ្នកទាំងអស់គ្នាគិតយ៉ាងណាដែរចំពោះសោតនាដកម្មមួយនេះ?

Links and Resources

https://murderpedia.org/male.H/h/hoffman-victor-ernest.htm
https://www.findagrave.com/memorial/111731070/victor-ernest-hoffman